FARMER NOTES
ព្រឹត្តិប័ត្រព័ត៌មានកសិករ
ឆ្នាំទី ១ លេខ ០៣ ខែសីហា ឆ្នាំ ២០០៦
ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# មូសផ្លុងលើដំណាំស្រូវ

## ១-លក្ខណៈទូទៅនៃមូសផ្លុង និងការបំផ្លាញរបស់វា



មូសផ្លុង (Orseolia oryzae) ជាសត្វល្អិតដែលមានរូបរាងតូច ដូចសត្វមូសធម្មតាដែរ។ ចំពោះមូសផ្លុងឈ្មោលពេញវ័យ ខ្លួនរបស់វាមានពណ៌លឿងត្នោត និងមានខ្លួនតូចជាងមូសផ្លុងញី ដែលមានពោះពណ៌ក្រហម។

នៅពេលភ្លៀងចាប់ផ្តើមធ្លាក់នាដើមរដូវវស្សា មូសផ្លុងពេញវ័យហើរចេញពីស្មៅចង្រៃមករកជម្រកថ្មីដែលមានចំណី និងអាចបន្តពូជបាន។ ចំពោះមូសផ្លុងញីនិមួយៗ អាចពងបានពី ១-៤ នៅលើស្លឹកស្រូវ និងមានជីវិតត្រឹមតែ ៤ ឬ ៥ ថ្ងៃប៉ុណ្ណោះ ប៉ុន្តែចាប់ពីពេលពេញវ័យរហូតដល់ងាប់ទៅវិញ វាអាចពងបានរាប់រយងណោះ។





ដង្កូវមូសផ្លុង ដែលញាស់ចេញពីពងមានពណ៌សស្រអាប់ ហើយចូលលាក់ខ្លួននៅក្នុងដើមស្រូវ និងស៊ីបំផ្លាញបណ្តូលក្នុងនៃដើមស្រូវ ដែលជាហេតុធ្វើឲ្យស្រូវមិនចេញកួរ។ ការបំផ្លាញដល់បណ្តូលខាងក្នុងនេះ មានសណ្ឋានជាបំពង់ ហាក់ដូចស្លឹកខ្ទឹមបារាំង ដែលគេនិយមហៅថា "ពកស្លឹកខ្ទឹមបារាំង"។ ឯការបំផ្លាញរបស់វាមានចាប់តាំងពីនៅវគ្គសំណាប រហូតដល់ចុងបញ្ចប់នៃវគ្គបែកគុម្ព។ នៅក្នុងប្រទេសកម្ពុជាយើង មូសផ្លុងមិនត្រូវបានគេចាត់ទុកជាកត្តាចង្រៃធ្ងន់ធ្ងរទេ។ ក្នុងនោះមានខេត្តមួយចំនួនដែលទទួលរងនូវការបំផ្លិចបំផ្លាញគួរឲ្យកត់សម្គាល់នោះមានដូចជា នៅខេត្តស្វាយរៀង ព្រៃវែង កំពត និងកំពង់ចាម។

## ២-វិធានការណ៍ការពារ

*ការបំផ្លាញរុក្ខជាតិទាំងឡាយជាជម្រក៖* ធ្វើការកាប់ឆ្ការសម្អាតស្មៅចង្រៃ ឬស្រងែដែលនៅជុំវិញបរិវេណស្រែ និងក្នុងស្រែនៅពេលដាំដុះ និងក្រោយពេលប្រមូលផល។



*ភ្ជួរស្រែបន្ទាប់ពីប្រមូលផល៖* ធ្វើដីឲ្យស្អាតល្អ កុំឲ្យមានរុក្ខជាតិជម្រក បន្ទាប់ពីច្រូតកាត់រួច។

*ពេលវេលាដាំដុះ៖* ត្រូវពន្យាពេលដាំដុះក្នុងរដូវវស្សាឲ្យបានសមស្របបើអាចធ្វើទៅបាន គឺធ្វើលើពូជស្រូវប្រកាន់រដូវ ដើម្បីកាត់បន្ថយវគ្គលូតលាស់របស់ស្រូវឲ្យនៅខ្លី។ ផ្ទុយទៅវិញ ធ្វើការដាំដុះពូជស្រូវមិនប្រកាន់រដូវ ឲ្យបានឆាប់រហ័សនៅពេលដើមរដូវវស្សា ដើម្បីឲ្យដំណាំស្រូវបានបញ្ចប់វគ្គលូតលាស់មុនពេលមូសផ្លុង បំលាស់ទីមកពីរុក្ខជាតិជម្រក ជាការប្រសើរ។

*ចៀសវាងការដាំដុះបន្តបន្ទាប់គ្នាឥតដាច់៖* ត្រូវដាំដុះកុំឲ្យយឺតជាងស្រែជិតខាង ៣ សប្តាហ៍។

*ការដាក់ជី៖* ការប្រើប្រាស់ជីអ៊ុយរ៉េ ក្នុងកម្រិតមធ្យម ហើយបាចវាជាបីដំណាក់កាល (ដំណាក់កាលសំណាប បែកគុម្ព និងកំណរកំណើតកួរ) ជាវិធីដ៏ល្អក្នុងការការពារជាមួយមូសផ្លង ដែលមានការបំផ្លាញ និងរាតត្បាត។



*ដំណាំបង្វិល (Crop Rotation)៖* ការដាំស្រូវបន្តគ្នារហូត អាចធ្វើឲ្យប្រជាកររបស់មូសផ្លងកើនឡើង។ ផ្ទុយមកវិញការទុកដីស្រែឲ្យនៅទំនេរ ឬការអនុវត្តការដាំដំណាំបង្វិល ដោយការថែទាំមិនឲ្យមានស្មៅអាចកាត់បន្ថយប្រជាករមូសផ្លងបានដែរ។

*ការប្រើប្រាស់ពូជធន់៖* ការដាំដុះពូជធន់ គឺជាវិធានការមួយប្រកបដោយប្រសិទ្ធភាពល្អបំផុតក្នុងការការពារពីការបំផ្លាញរបស់មូសផ្លង។ ការពិសោធន៍តាមដានពូជស្រូវធន់ទ្រាំទៅនឹងការបំផ្លាញរបស់មូសផ្លង កំពុងតែប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា។ តាមលទ្ធផលពិសោធន៍ដំបូងខាងលើនេះ គឺមានពូជប្រពៃណីកម្ពុជាមួយចំនួនដូចជា ឈុត្តនា នាងមិញ និងសូម៉ាលី ហើយនិងពូជស្រូវទំនើបដូចជា IR36 និង IR42 ដែលអាចយកមកប្រើប្រាស់ជាមេបាក្នុងការបង្កើតពូជថ្មីគឺមានភាពធន់ទៅនឹងការបំផ្លាញរបស់មូសផ្លង។

## ៣-ការកម្ចាត់

**ការ**បាញ់ថ្នាំសម្លាប់សត្វល្អិតប្រភេទពុលខ្លាំង ដើម្បីកម្ចាត់ប្រភេទសត្វល្អិតចង្រៃណាមួយ អាចធ្វើឲ្យមានការរាតត្បាតដោយមូសផ្លងកាន់តែខ្លាំងឡើងថែមទៀត គឺដោយសារថ្នាំនោះបានសម្លាប់ពពួកសត្វល្អិតមានប្រយោជន៍ ដូចជាពីងពាងពួកឪម៉ាល់ និងប៉ារ៉ាស៊ីត ដែលជាសត្រូវធម្មជាតិសម្រាប់ការសម្លាប់មូសផ្លង។ ការកម្ចាត់មូសផ្លង ដោយប្រើថ្នាំសម្លាប់សត្វល្អិត មានការលំបាកជាទីបំផុត ព្រោះដង្កូវមូសផ្លង វារស់នៅក្នុងដើមស្រូវ។ ប្រភេទថ្នាំសម្លាប់សត្វល្អិតជ្រាប (Systemic insecticide) ដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការកម្ចាត់មូសផ្លងនោះ គឺមានតែថ្នាំរីជែន (Regen) ឬ (Fipronil) មួយគត់ នៅក្នុងប្រទេសកម្ពុជា។ ថ្នាំនេះមានទម្រង់ពីរយ៉ាង មួយជាគ្រាប់ និងមួយទៀតជាទឹក។ ថ្នាំហ្វីប្រូនីល (Fipronil) ទម្រង់ជាគ្រាប់ មានប្រសិទ្ធភាពខ្ពស់ក្នុងការកម្ចាត់មូសផ្លង ជាជាងប្រភេទថ្នាំទឹក បើសិនជានៅក្នុងស្រែនោះមានទឹកជាអចិន្ត្រៃយ៍។ ការប្រើថ្នាំគ្រាប់ហ្វីប្រូនីល (Fipronil) លើថ្នាលសំណាបមុននឹងយកទៅស្ទូងក្នុងរយៈពេលពី ១ ទៅ ២ សប្តាហ៍អាចការពារការបំផ្លាញធ្ងន់ធ្ងរពីមូសផ្លងបាន។ សរុបមក មុនពេលសម្រេចចិត្តប្រើប្រាស់ថ្នាំគីមីនេះ ត្រូវគិតទៅដល់សេដ្ឋកិច្ច បរិស្ថាន និងសុខភាពជាមុនសិន ថាតើគួរប្រើ ឬមិនគួរ ហើយត្រូវកំណត់ឲ្យបានច្បាស់ចៀសវាង ការប្រើទាំងប្រថុយប្រថាន។




តំបន់រាតត្បាតដោយមូសស្រូវ

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យការពារដំណាំ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh

ទូរអក្សរ: plap@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh